00865072

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 11 / 2012
ម៉ោង (Time/Heure) : 14 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E238/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ជូនចំពោះ:** មេធាវីការពារក្តី អៀង សារី , សហព្រះរាជអាជ្ញា, សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, មន្ត្រីទទួលបន្ទុកសំណុំរឿងនៃអង្គជំនុំជម្រះសាលាដំបូង, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ, ការិយាល័យរដ្ឋបាល

**កម្មវត្ថុ:** ចម្លើយតបទៅនឹងការសាកសួររបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងហេតុការណ៍កាលពីថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០១២

ក្រោយពេលសវនាការកាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានផ្ញើទៅសាស្ត្រាចារ្យ A. John CAMPBELL នូវរាល់ឯកសារទាំងអស់ពាក់ព័ន្ធនឹងការសម្រាកព្យាបាលនៅមន្ទីរពេទ្យនាពេលថ្មីៗរបស់ជនជាប់ចោទ អៀង សារី (ឯកសារ E233)។ កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានតែងតាំងសាស្ត្រាចារ្យ CAMPBELL ដើម្បីពិនិត្យសុខភាពជនជាប់ចោទ អៀង សារី បន្ថែមទៀត និងពិគ្រោះយោបល់ជាមួយបុគ្គលដែលមានគុណវុឌ្ឍិផ្សេងៗ ធ្វើតេស្តសុខភាពរបស់ អៀង សារី និងធ្វើរបាយការណ៍ស្តីពីសុខភាពរបស់ជនជាប់ចោទ (ឯកសារ E238)។ កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ មេធាវីការពារក្តី អៀង សារី (“មេធាវីការពារក្តី”) បានស្នើសុំឱ្យអង្គជំនុំជម្រះពិនិត្យហេតុការណ៍មួយដែលបានកើតឡើងកាលពីថ្ងៃទី ១៦ និងថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២ ដែលហាក់ដូចជាពុំមានការបញ្ជាក់ក្នុងរបាយការណ៍វេជ្ជសាស្ត្រជាប្រក្រតីដែលត្រូវបានប្រគល់ទៅអង្គជំនុំជម្រះ។ យោងតាមមេធាវីការពារក្តី ជនជាប់ចោទបានចាប់ផ្តើមក្អក និងក្អួត ប៉ុន្តែពុំមានវេជ្ជបណ្ឌិតណាម្នាក់បានឆ្លើយតបទាន់ពេលវេលាឡើយ។ ក្រោយមកទៀត មេធាវីការពារក្តីបានស្នើសុំការជូនដំណឹងទៅអ្នកជំនាញដែលតុលាការបានតែងតាំងឱ្យបានជ្រាបអំពីហេតុការណ៍នេះ។

នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានសាកសួរការិយាល័យរដ្ឋបាល ដើម្បីសាកសួរបន្តទៅមន្ទីរពេទ្យអំពីមូលហេតុដែលហេតុការណ៍នៃការក្អួតនេះ មិនត្រូវបានបង្ហាញនៅក្នុងរបាយការណ៍វេជ្ជសាស្ត្រប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ ដែលត្រូវប្រគល់ឱ្យមកអង្គជំនុំជម្រះ។ នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានទទួលពត៌មានថា អំឡុងពេលនៃហេតុការណ៍នោះ វេជ្ជបណ្ឌិតមិនបានដឹងពីការគោះទ្វារហៅនោះទេ។ ទោះយ៉ាងណាក៏ដោយ មានការទទួលស្គាល់ថា មន្ទីរពេទ្យនឹងខិតខំធ្វើឱ្យបានប្រសើរឡើងនូវការឆ្លើយតបរបស់ខ្លួនចំពោះអ្នកជម្ងឺ។ សេចក្តីបារម្ភរបស់ក្រុមការពារក្តី អៀង សារី ត្រូវបានផ្តល់ជូនទៅវេជ្ជបណ្ឌិត ហើយមន្ទីរពេទ្យក៏បានចាប់ផ្តើមដំឡើងកណ្តឹងនៅក្នុងបន្ទប់អ្នកជម្ងឺ ដើម្បីឱ្យអ្នកជម្ងឺ ឬអ្នកមើលថែទាំអ្នកជម្ងឺអាចហៅវេជ្ជបណ្ឌិតក្នុងករណីបន្ទាន់ៗ។ ខាងមន្ទីរពេទ្យក៏បានយល់ព្រមដែរថា វេជ្ជបណ្ឌិតរបស់ខ្លួននឹងដាក់បញ្ចូលរាល់បញ្ហា ដូចជាការក្អួតជាដើម នៅក្នុងរបាយការណ៍វេជ្ជសាស្ត្រដែលត្រូវផ្តល់មកអង្គជំនុំជម្រះនាពេលអនាគត។ សេចក្តីរាយការណ៍ក៏បានឱ្យដឹងដែរថា អ្នកព្យាបាលដោយចលនាទៅលើជនជាប់ចោទ អៀង សារី បានទៅជួបគាត់ចំនួនពីរបីដងក្នុងមួយសប្តាហ៍ ចាប់តាំងពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ ដែលផ្ទុយពីសេចក្តីបញ្ជាក់នៅក្នុងលិខិតរបស់ក្រុមការពារក្តី អៀង សារី។

ក្រោយសវនាការថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំសាស្ត្រាចារ្យ Campbell តាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ឱ្យបញ្ជាក់បំភ្លឺអំពីកាលៈទេសៈជុំវិញការក្អួតរបស់ជនជាប់ចោទ។ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានទទួលចម្លើយតបរបស់សាស្ត្រាចារ្យ CAMPBELL តាមរយៈសារអេឡិចត្រូនិកដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

> ការធ្វើអត្ថាធិប្បាយណាមួយអំពីការក្អួតនេះ គឺជាការពិបាក។ ការក្អួតនេះអាចត្រូវបានដោះស្រាយយ៉ាងសមស្របដោយបុគ្គលិកគិលានុបដ្ឋាក គិលានុបដ្ឋាយិកា។ នៅពេលអ្នកជំងឺក្អួតម្តងៗ វេជ្ជបណ្ឌិតពុំចាំបាច់ទទួលបានការជូនដំណឹងឡើយ។ អាការៈវិលមុខធីងធោងរបស់ អៀង សារី អាចបណ្តាលឱ្យគាត់រកកលចង់ក្អួត និងជួនកាលអាចធ្វើឱ្យគាត់ក្អួត។ ប្រសិនបើការក្អួតនេះចេះតែកើតមានឥតឈប់ឈរ និងអាចបណ្តាលឱ្យបាត់បង់ជាតិទឹក ទើបការក្អួតនេះមានភាពគួរឱ្យកត់សម្គាល់ និងត្រូវការអន្តរាគមន៍។ ខ្ញុំពុំយល់ឃើញថា ការពុំបានលើកឡើងអំពីហេតុការណ៍នេះនៅក្នុងកំណត់ហេតុវេជ្ជសាស្ត្រ គឺជាការធ្វេសប្រហែសធ្ងន់ធ្ងរឡើយ។